មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៧ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

| | |
|---|---|
| ឈ្មោះស្ថាប័ន | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") |
| គោលដៅគម្រោង | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក គឺជាអង្គការឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារផ្អែកទៅលើតម្លៃសមភាព អព្យាក្រឹត្យភាព តម្លាភាព និងការមិនរើសអើង។ |
| រយៈពេល | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៧ |

ក្នុងអំឡុងឆ្នាំ២០១៧ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានអនុវត្តសកម្មភាពការងាររបស់ខ្លួនដូចមានរៀបរាប់ខាងក្រោម ៖

## ១. វឌ្ឍនភាពនៃសកម្មភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានចេញផ្សាយឯកសារផ្សព្វផ្សាយ ចំនួន ៦៧ ទាក់ទងនឹងសិទ្ធិមនុស្សក្នុងនោះរួមមានសេចក្តីថ្លែងការណ៍ សេចក្តីថ្លែងការណ៍រួម លិខិតចំហ សេចក្តីប្រកាសព័ត៌មានបន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន ការវិភាគច្បាប់ សារណារួម គោលនយោបាយសង្ខេប និងខិត្តប័ណ្ណព័ត៌មាន។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងការស្វែងរកការគាំទ្រ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនផ្សេងៗទៀត រួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ច និងសិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ សិទ្ធិជនជាតិដើមភាគតិច និងការចូលរួមក្នុងនយោបាយ។

ជាលទ្ធផលនៃការបន្តឃ្លាំមើលសារព័ត៌មាននៅឆ្នាំ២០១៧ ម.ស.ម.ក បានឃ្លាំមើលសារព័ត៌មានក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានា និងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតសំខាន់ទៅលើសិទ្ធិដីធ្លី ធុរកិច្ច និងសិទ្ធិមនុស្សជាទូទៅ សិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នក

ស្រឡាញ់ទាំងពីរភេទនិងអ្នកប្តូរភេទ("អ្នកស្រឡាញ់ភេទដូចគ្នា") និងស្ថានភាពនៃសេរីភាពមូលដ្ឋាននៅទូទាំងប្រទេស។ ជាសរុបក្នុងឆ្នាំ២០១៧ នេះ ម.ស.ម.ក បានប្រមូលព័ត៌មានសរុបចំនួន១៧៥៥ អត្ថបទដែលចេញផ្សាយពាក់ព័ន្ធនឹងសេរីភាពខាងការជួបប្រជុំ និងសេរីភាពជាមូលដ្ឋានផ្សេងទៀត ព្រមទាំងបានប្រមូលអត្ថបទព័ត៌មានចំនួន៣៣៤ ពាក់ព័ន្ធនឹងករណីជម្លោះដីធ្លី។

គម្រោង ធុរកិច្ច និងសិទ្ធិមនុស្ស ហើយនិងគម្រោងសុវត្ថិភាពកាន់កាប់ដីធ្លី បានចេញផ្សាយសលាកបត្រព័ត៌មានអំពី <u>ការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុននិងទទួលបានព័ត៌មានពេញលេញ</u> ក្នុងខែសីហា ឆ្នាំ២០១៧ នៅក្នុងឱកាសនៃទិវាលំនៅដ្ឋានពិភពលោក និងចូលរួមគាំទ្រសេចក្តីថ្លែងការណ៍រួមមួយស្តីពី "<u>អង្គការសង្គមស៊ីវិលសូមអំពាវនាវដល់សាលារាជធានីភ្នំពេញទម្លាក់ចោលឱសានវាទចំពោះប្រជាពលរដ្ឋជាច្រើនគ្រួសារនៅបុរីកីឡានិងសូមផ្តល់សំណងសមរម្យជូនពួកគាត់ដោយកុំពន្យារពេល</u>" ក្នុងខែធ្នូ ឆ្នាំ២០១៧។ ជាមួយគ្នានេះផងដែរ មានឯកសារចេញផ្សាយផ្សេងទៀតត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនដូចជា សេចក្តីថ្លែងការណ៍រួមអំពីករណីនៅបុរីកីឡាបាននាំទៅរកការផ្លាស់ប្តូរវិជ្ជមាន ព្រោះជាលទ្ធផល អាជ្ញាធរបានបន្តពិភាក្សាជាមួយសហគមន៍ដែលរងផលប៉ះពាល់។

បន្ថែមពីនេះទៀត ម.ស.ម.ក បានរៀបចំការផ្សាយបន្តផ្ទាល់កម្មវិធីវិទ្យុចំនួន ១៦១ លើក ដោយកម្មវិធីនីមួយៗផ្តោតទៅលើប្រធានបទដែលបានរៀបរាប់ខាងលើ ក្នុងនោះរួមមាន កម្មវិធីពិភាក្សាទាក់ទងនឹងសិទ្ធិដីធ្លី ធុរកិច្ច និងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ការពិភាក្សាផ្នែកច្បាប់ និងការវិភាគប្រចាំសប្តាហ៍ជាដើម។ ក្នុងកម្មវិធីទាំងនោះសុទ្ធមានអញ្ជើញវាគ្មិនសំខាន់ៗមកពីអង្គការសង្គមស៊ីវិល និងអាជ្ញាធរដើម្បីចូលរួមចែករំលែកគំនិតយោបល់។ ក្នុងចំណោមកម្មវិធីពិភាក្សាចំនួន១៦១ មានកម្មវិធីចំនួន១២៤ ត្រូវបានផ្សាយបន្តផ្ទាល់តាមទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ដែលទទួលបាន Like សរុបចំនួន ១០,១៥៧ ចែករំលែកបន្តចំនួន ៥,៤០៦ និងចូលទៅទស្សនាចំនួន ២៣២,០៦៧ ។

ម.ស.ម.ក បានរៀបចំកម្មវិធីផ្សព្វផ្សាយរបាយការណ៍ចំនួនពីរលើក និងការបណ្តុះបណ្តាលចំនួន៣ វគ្គពាក់ព័ន្ធនឹងប្រធានបទផ្សេងៗគ្នាដូចជា ជំនាញស្វែងរកការគាំទ្រ គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ច្បាប់ភូមិបាល សិទ្ធិពាក់ព័ន្ធនឹងសញ្ជាតិ។ ម.ស.ម.ក បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់អំពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ ("យូភីអ") ជាមួយដៃគូពាក់ព័ន្ធផ្សេងៗក្នុងនោះក៏មានការចូលរួមសហការរៀបចំពីសំណាក់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងបានឃ្លាំមើលវគ្គបណ្តុះបណ្តាលសហគមន៍ចំនួន ៥ វគ្គ។ ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ខ្លួនក្នុងឆ្នាំ២០១៧ ម.ស.ម.ក បានឃ្លាំមើលសវនាការនៅសាលាឧទ្ធរណ៍ចំនួន២៤៥ ករណី។ ជាចុងក្រោយ ម.ស.ម.ក បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ឬ/តំណាងជាមេធាវីនិងជំនួយមនុស្សធម៌ចំនួន៣១ ករណី នៅក្នុងឆ្នាំ២០១៧។

គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័របានចេញផ្សាយរបាយការណ៍ស្តីពី " គ្រួសារឥន្ទធនូនៅកម្ពុជា"[1] ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។ របកគំហើញលើកឡើងក្នុងរបាយការណ៍នេះផ្អែកទៅលើការស្រាវជ្រាវលើឯកសារ និងការចុះទៅស្រាវជ្រាវផ្ទាល់នៅចន្លោះខែកុម្ភៈ និងខែមិថុនា ឆ្នាំ២០១៧ ដែលបានផ្តោតលើបញ្ហាជាក់លាក់ចំនួនបីរួមមាន អាពាហ៍ពិពាហ៍ ការសុំកូន និងការទទួលស្គាល់យេនឌ័រ។ ការស្រាវជ្រាវធ្វើឡើងតាមរយៈការសម្ភាសជាមួយគូស្រករស្រឡាញ់ភេទដូចគ្នាដែលរស់នៅជាមួយគ្នា អតីតគូស្រករដែលធ្លាប់រស់នៅជាមួយគ្នា អាជ្ញាធរមូលដ្ឋាន និងតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ចំនួន១២១ កិច្ចសម្ភាស នៅទូទាំង ១០ ខេត្ត ។ របាយការណ៍នេះបង្ហាញនូវព័ត៌មានដែលពុំបានរាយការណ៍ពីមុនៗអំពីគូស្រករស្រឡាញ់ភេទដូចគ្នានិងគ្រួសារស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ របាយការណ៍នេះបង្ហាញថា ទោះបីជាសមភាពអាពាហ៍ពិពាហ៍មិនអាចធ្វើទៅបានយោងតាមរដ្ឋធម្មនុញ្ញកម្ពុជាក្តី ក៏មានគូស្រករស្រឡាញ់ភេទដូចគ្នាជាច្រើនកំពុងរស់នៅជាប្តីប្រពន្ធជាមួយគ្នារួចហើយ គូស្រករខ្លះបានរៀបចំកម្មវិធីអាពាហ៍ពិពាហ៍ក្រៅផ្លូវការ ហើយមានចំនួន ២១.៥០% គូស្រករដែលបានសម្ភាសបញ្ជាក់ថាពួកគាត់ទទួលការទទួលស្គាល់ជាផ្លូវការតាមផ្លូវច្បាប់នៅក្នុងទម្រង់សៀវភៅគ្រួសារដែលបានចេញដោយអាជ្ញាធរឃុំ។ម្យ៉ាងវិញទៀត របាយការណ៍នេះក៏បានបង្ហាញពីភាពខុសគ្នាជាច្រើនរវាងខេត្តផ្សេងៗទាក់ទងនឹងលទ្ធភាពទទួលបានសៀវភៅគ្រួសារសម្រាប់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ នៅតាមខេត្តមួយចំនួន គូស្រករស្រឡាញ់ភេទដូចគ្នាភាគច្រើនបានទទួលសៀវភៅគ្រួសារ ចំណែកនៅខេត្តផ្សេងទៀតនៅពុំទាន់ទទួលបានច្រើននៅឡើយ។ លទ្ធផលនៃរបាយការណ៍នេះបង្ហាញពីលក្ខណៈវិជ្ជមានមួយចំនួន បន្ទាប់ពីមានកិច្ចប្រជុំនានាជាមួយក្រសួងមួយចំនួនដូចជាក្រសួងយុត្តិធម៌និងក្រសួងមហាផ្ទៃ។ កិច្ចប្រជុំទាំងពីរមានគោលបំណងបង្ហាញអំពីរបកគំហើញស្រាវជ្រាវសំខាន់ៗអំពីស្ថានភាព និងបញ្ហាប្រឈមរបស់គ្រួសារនៃគូស្រករអ្នកស្រឡាញ់ភេទដូចគ្នានិងលើកឡើងនូវអនុសាសន៍សំខាន់ៗមួយចំនួន។ កិច្ចប្រជុំនេះគឺជាកាលានុវត្តភាពមួយ ដើម្បីជំរុញឱ្យអាជ្ញាធរទទួលបានការយល់ដឹងប្រសើរជាងមុនអំពីគ្រួសារនៃគូស្រករស្រឡាញ់ភេទដូចគ្នា។ ក្នុងពេលការប្រជុំទាំងពីរនេះ ភាគីទាំងអស់បានឯកភាពគ្នាលើសារៈសំខាន់នៃការធានាដល់ការលើកកម្ពស់ និងការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ ជាចុងក្រោយ ម.ស.ម.ក បានលើកឡើងពីភាពចាំបាច់ក្នុងការចាត់វិធានការភ្លាមៗដើម្បីទទួលបានការទទួលស្គាល់យេនឌ័រ ការសម្រួលដល់ការសុំកូន និងធានាដល់ការការពារសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នា។

ម.ស.ម.ក ក៏បានផលិតវីដេអូអប់រំចំនួនពីរផងដែរ។ វីដេអូទី១ ស្តីពី "យុត្តិធម៌ខ្ញុំ" ផលិតឡើងក្នុងគោលបំណងបង្ហាញអំពីជនត្រូវចោទប្រកាន់នូវបទល្មើសព្រហ្មទណ្ឌនឹងមានសិទ្ធិទទួលបានសិទ្ធិជំនុំជម្រះដោយយុត្តិធម៌រួមមាន ១) សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ២) សិទ្ធិទទួលបានការជំនុំជម្រះពីសាលាក្តីឯករាជ្យនិងឥតលម្អៀង ៣) សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ៤) សិទ្ធិទទួលបានការជំនុំជម្រះដោយពុំពន្យារពេល តាមរយៈការសម្តែងរឿងនេះ។ វីដេអូនេះ

[1] គ្រួសារឥន្ទធនូ គឺជាពាក្យជំនួសមួយដែលត្រូវគេប្រើក្នុងរបាយការណ៍នេះដើម្បីហៅគ្រួសារនៃគូស្រករអ្នកស្រឡាញ់ភេទដូចគ្នា ឬដៃគូម្ខាង ឬដៃគូទាំងពីរនាក់ជាអ្នកប្តូរភេទ។

ត្រូវបានផ្សព្វផ្សាយនៅលើយូធូប និងនៅលើទំព័រហ្វេសប៊ុករបស់ម.ស.ម.ក។ វីដេអូនេះទទួលបានការគាំទ្រជាច្រើននៅលើទំព័រហ្វេសប៊ុកដែលមានការចែករំលែកបន្តចំនួន៣,០០០ និងចុច Like ចំនួន ៥,៨០០ និងចូលទស្សនាចំនួន ៩៧,០០០[2] (គិតមកត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨)។ វីដេអូទី២ ស្តីពី "គូស្រករឥន្ទធនូ" បានរៀបរាប់អំពីបទពិសោធន៍និងទស្សនៈរបស់គូស្រករស្រឡាញ់ភេទដូចគ្នាពីរគូ៖ គូស្រករមួយគូជិតរៀបចំអាពាហ៍ពិពាហ៍របស់ពួកគេក្នុងខេត្តព្រះវិហារ និងមួយគូទៀតមានទំនាក់ទំនងរស់នៅជាមួយគ្នាអស់រយៈពេល៣០ឆ្នាំមកហើយ។ លើសពីនេះ ឯកឧត្តម ជិន ម៉ាលីន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានពន្យល់អំពីច្បាប់កម្ពុជាទាក់ទងនឹងអាពាហ៍ពិពាហ៍ភេទដូចគ្នា។ វីដេអូនេះត្រូវបានផ្សព្វផ្សាយតាមរយៈយូធូប និងទំព័រហ្វេសប៊ុករបស់ម.ស.ម.ក។ វីដេអូនេះទទួលបានការចែករំលែកបន្តចំនួន ៤៧ Like ចំនួន៦៦ និងចូលទស្សនាចំនួន ៥៤០០ (គិតនៅត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨)។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ម.ស.ម.ក បានផលិតខិត្តប័ណ្ណអប់រំចំនួន ៤ ផងដែរ ទាក់ទងនឹងសិទ្ធិជំនុំជម្រះដោយយុត្តិធម៌ រួមមាន ១) សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ២) សិទ្ធិទទួលបានការជំនុំជម្រះពីសាលាក្តីឯករាជ្យ និងឥតលម្អៀង ៣) សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ៤) សិទ្ធិទទួលបានការជំនុំជម្រះដោយពុំពន្យារពេល។

ម.ស.ម.ក បានចេញផ្សាយខិត្តប័ណ្ណមួយផងដែរស្តីពី ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងប្រទេសកម្ពុជា ធ្វើបច្ចុប្បន្នភាពត្រឹមខែសីហា ឆ្នាំ២០១៧។

## ២. សកម្មភាពដែលដំណើរការបានល្អ និងមិនល្អ

មានចំនុចជោគជ័យជាច្រើនសម្រាប់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា តាមរយៈគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ ការចេញផ្សាយរបាយការណ៍ស្តីពី គ្រួសារឥន្ទធនូនៅកម្ពុជា មានផលជះខ្លាំងជុំវិញការមើលឃើញពីការរើសអើង និងបញ្ហាប្រឈមរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដោយសារបានយល់ និងទទួលយកបញ្ហានេះជាវិជ្ជមាន។របាយការណ៍នេះក៏ផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់ការតស៊ូមតិផងដែរ។ គម្រោងយូភីអ មានការចូលរួមសហការជាមួយស្ថាប័នរដ្ឋាភិបាលមានដូចជា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រសួងយុត្តិធម៌ ដែលជាផ្នែកមួយនៃការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ពាក់កណ្តាលអាណត្តិរបស់កម្ពុជាក្នុងខែមិថុនា ឆ្នាំ២០១៧។

បន្ទាប់ពីការបោះឆ្នោតឃុំ/សង្កាត់ ក្នុងខែមិថុនា ឆ្នាំ២០១៧ ស្ថានភាពសិទ្ធិមនុស្សនិងនយោបាយនៅមានលក្ខណៈប្រឈមខ្លាំង ហើយលំហសម្រាប់សង្គមស៊ីវិលធ្វើសកម្មភាពការងារកាន់តែរួមតូចទៅ។ ប្រការនេះកាន់តែលំបាកខ្លាំងឡើងសម្រាប់អង្គការសង្គមស៊ីវិលក្នុងការបំពេញការងាររបស់ពួកគេ ហើយមានការដៅមុខសញ្ញាទៅលើអង្គការសង្គមស៊ីវិលផងដែរ។ តួយ៉ាង ម.ស.ម.ក បានប្រឈមផ្ទាល់នឹងការគំរាមថានឹងត្រូវបិទស្ថា

[2] ការចូលទស្សនា៖ ជាចំនួនពេលវេលាដែលត្រូវបានវាយតម្លៃលើវីដេអូដែលបង្ហោះយ៉ាងតិច៣វិនាទី ប្រភព៖ http://bit.ly/1upJLvd.

ប័ន ប៉ុន្តែត្រូវបានអនុញ្ញាតិឱ្យប្រតិបត្តិការបន្តទៀតបន្ទាប់ពីការមិនរកឃើញនូវកំហុសណាមួយ និងថែមទាំងទទួលបានការទទួលស្គាល់ថា ស្ថាប័ននេះបានចូលរួមចំណែកក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។

លើសពីនេះ តំណាងសហគមន៍នៅតាមខេត្តមួយចំនួនបានប្រឈមនឹងការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែង រារាំងពួកគាត់ក្នុងការទាក់ទងជាមួយភាគីពាក់ព័ន្ធខាងក្រៅដើម្បីចូលរួមប្រជុំ និងការបណ្តុះបណ្តាលជាមួយអង្គការ និងការរៀបចំកម្មវិធីនានានៅតាមមូលដ្ឋាន។

## ៣. មេរៀន

ថ្វីបើមានការប្រឈមយ៉ាងណាក្តី ម.ស.ម.ក យល់ឃើញថាការបន្តសកម្មភាពប្រកបដោយគោលការណ៍ និងការចូលរួមក្នុងកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធជាកិច្ចការចាំបាច់ដើម្បីបន្តកិច្ចគាំពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ ម.ស.ម.ក នៅតែប្រកាន់គោលជំហរប្រកបដោយគោលការណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ទស្សនៈមិនលម្អៀង និងគុណភាព។

## ៤. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ម.ស.ម.ក ប្រឹងប្រែងដើម្បីសម្រេចបានសមភាពយេនឌ័រតាមរយៈកម្មវិធី និងគម្រោងនានាទាំងអស់របស់ខ្លួន។ នៅឆ្នាំ២០១៧ ម.ស.ម.ក ព្យាយាមជំនះឧបសគ្គនានាដើម្បីឱ្យមានការចូលរួមរបស់ស្ត្រី ដូចជាការជានាភាពជាតំណាងស្មើភាពគ្នារវាងបុរសនិងស្ត្រីនៅក្នុងកម្មវិធីនានា នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងលើកឡើងពីឋានៈផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស និងស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

ម្យ៉ាងវិញទៀត ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដើម្បីលើកកម្ពស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីក្នុងទិវានារីអន្តរជាតិ ថ្ងៃ០៨ ខែមីនា ឆ្នាំ២០១៧ និងនៅតែបន្តផ្តល់ការគាំទ្រផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលបានប្រឈមនឹងអំពើហិង្សាការយាយី និងការគំរាមកំហែងដល់ការងាររបស់ពួកគេ។

**៥. ឧបសម្ព័ន្ធ ៖** ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក

- របាយការណ៍ស្តីពីគ្រួសារឥន្ទធនូនៅកម្ពុជា
- វីដេអូស្តីពី គ្រួសារឥន្ទធនូនៅកម្ពុជា
- វីដេអូស្តីពី យុត្តិធម៌ខ្ញុំ
- ខិត្តប័ណ្ណស្តីពី សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- ខិត្តប័ណ្ណស្តីពី សិទ្ធិទទួលបានការជំនុំជម្រះពីសាលាក្តីឯករាជ្យ និងឥតលម្អៀង
- ខិត្តប័ណ្ណស្តីពី សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- ខិត្តប័ណ្ណស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយពុំពន្យារពេល

---ចប់---